ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមិថុនា ឆ្នាំ២០១៩

នៅក្នុងខែមិថុនា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញការកិច្ចដូចតទៅ:

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញទទួលព្រះរាជដំណើរព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងនិវត្តន៍ពីប្រទេសបារាំងបន្ទាប់ពីព្រះអង្គយាងចូលរួមប្រារព្ធពិធីអបអរសាទរខួបលើកទី២៥ឆ្នាំ នៃសកម្មភាពគណៈ-កម្មាធិការ អន្តរជាតិសម្របសម្រួលកិច្ចការគាំពារ និងអភិរក្សតំបន់អង្គរ ដែលហៅកាត់ថា ICC-Angkor

-អញ្ជើញចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល គម្រប់៨៣ យាងចូល៨៤ ព្រះវស្សា នៅព្រះរាជដំណាក់សិរីមង្គល ក្នុងព្រះបរមរាជវាំង

-អនុញ្ញាតឱ្យឯកឧត្តម Dionisio da Costa Babo Soares រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ចូលជួបសម្តែងការគួរសម និងសវនាការ

-អញ្ជើញចុះពិនិត្យអគារសិក្សានៅក្នុងវិទ្យាល័យ ដីហែ ព្រមទាំងបានជួបសំណេះសំណាល និងសាកសួរសុខទុក្ខ លោកគ្រូ អ្នកគ្រូ និងអាជ្ញាធរមូលដ្ឋាន ស្រុក និងខេត្ត

-អញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខជាមួយមន្ត្រី អាជ្ញាធរសង្កាត់ព្រែកឯង និងប្រជាពលរដ្ឋ នៅខណ្ឌពោធិ៍សែនជ័យ និងខណ្ឌច្បារអំពៅ រាជធានី-ភ្នំពេញ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញជាអធិបតីក្នុងពិធីជួបជុំពិសារនំបញ្ចុកសាមគ្គី និងឯកភាពជាតិខ្មែរ

-អញ្ជើញចូលរួមពិធីបុណ្យខួប៤ឆ្នាំ និងខួប១០ឆ្នាំ ដើម្បីឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជាស៊ីម** នៅខណ្ឌចំការមន រាជធានីភ្នំពេញ

-អញ្ជើញជាអធិបតីក្នុងពិធីបុណ្យសព និងបុណ្យខួបគម្រប់៧ថ្ងៃ សពលោកជំទាវ **ផ្ទេក ភិរុណ** អតីតប្រធានកាកបាទក្រហមកម្ពុជា និងជាអតីតអគ្គលេខាធិការរដ្ឋសភា នៅបរិវេណវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះសព លោកជំទាវ **ផ្ទេក ភិរុណ** នៅវត្តភូមិម្ចុម៉ឺន ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល

-អញ្ជើញចូលរួមពិធីបុណ្យសព ឯកឧត្តម **ឃឹម សារិទ្ធ** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅវត្តព្រះមហោសថសុវណ្ណគីរីបឹងដែង (ហៅវត្តផ្កាឈូកមាស) ស្ថិតក្នុងភូមិបឹងដែង ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៦២ច្បាប់។

**១.២-ឯកឧត្តម ស៊ុំ កា អនុប្រធានទី១ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមប្រជុំក្រុមសមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៤ច្បាប់ និងជូនជ្រាបជាព័ត៌មាន ចំនួន២៤ច្បាប់។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតឱ្យគណៈប្រតិភូចិនដឹកនាំដោយឯកឧត្តម WAN Gang អនុប្រធានក្រុមប្រឹក្សាលើកកម្ពស់ការបង្រួបបង្រួមសន្តិភាពជាតិ និងជាអនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិនចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ព្រមទាំងអញ្ជើញជាអធិបតីក្នុងពិធីជប់លៀងជូនគណៈប្រតិភូក្នុងឱកាសដែលឯកឧត្តមមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបិទអង្គសិក្ខាសាលាស្តីពី ការឈ្វេងយល់អំពីសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសំណេះសំណាលជាមួយកុមារគ ថ្លង់ ពិការភ្នែក និងប្រជាពលរដ្ឋ ដើម្បីអបអរសាទរទិវាកុមារអន្តរជាតិលើកទី៧០នៅមជ្ឈមណ្ឌលកុមារកំព្រា ខេត្តកំពង់ចាម

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល

-អញ្ជើញដឹកនាំប្រជុំគណៈប្រតិភូ ដែលនឹងត្រៀមអញ្ជើញទៅចូលរួមវេទិកាអន្តរជាតិលើកទី២ស្តីពី ការអភិវឌ្ឍប្រព័ន្ធសភានិយម នៅសហព័ន្ធរុស្ស៊ី

-អញ្ជើញជាអធិបតីក្នុងពិធីប្រគល់ និងទទួលអំណោយ ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន

-បានឧបត្ថម្ភថវិកាជូនឃុំក្រាំងយ៉ូវ ឃុំព្រះពុទ្ធ និងសង្កាត់កំពង់សំណាញ់ ខេត្តកណ្តាល សម្រាប់រៀបចំកម្មវិធីពិសារនំបញ្ចុកសាមគ្គី ព្រមទាំងកុំព្យូទ័រយួរដៃមួយគ្រឿងជូនលោកស្រីអភិបាលរងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

-អញ្ជើញចូលរួមក្នុងកម្មវិធីពិសារនំបញ្ចុកសាមគ្គីជាមួយថ្នាក់ដឹកនាំព្រឹទ្ធសភានិងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់២៧ឆ្នាំ និងអភិសេកដើម្បីឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធព្រះសពរបស់ព្រះគ្រូទេពមុនី **គង់ យុន** នៅវត្តទេពប្រណម្យ ស្ថិតនៅភូមិភ្នំសន្ទះ ឃុំអង្គប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ផ្ទេក ភិរុណ** អតីតប្រធានកាកបាទក្រហមកម្ពុជា និងជាអតីតអគ្គលេខាធិការរដ្ឋសភា ដែលបានទទួលមរណភាពដោយជរាពាធ នៅវត្តបទុមវតី

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ និងចូលរួមបុណ្យសពឯកឧត្តម **ឃឹម សារិទ្ធ** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលទទួលមរណភាពដោយរោគាពាធ នៅខេត្តកំពង់ចាម

-អញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៤ឆ្នាំ និងគម្រប់១០ឆ្នាំ ឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធសម្តេច **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជាស៊ីម** នៅខណ្ឌចំការមន រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១១ច្បាប់។

## ២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក:

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោម:

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេសស្តីពី ការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ែតស្តីពី ការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគីស្តីពី ការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៥-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការបង្កើតអង្គការបណ្តាញអន្តរជាតិសម្រាប់ឫស្សី និងផ្តៅ

៦-កំណត់របៀបវារៈ និងកាលបរិច្ឆេទសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៤។

## ៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក :

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គចំនួន០១លើកដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេសស្តីពី ការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉េតស្ដីពី ការជំរុញ និងការការពារ ទៅវិញទៅមកនៃវិនិយោគ

៤-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគីស្ដីពី ការជំរុញ និងការ ការពារទៅវិញទៅមកនៃវិនិយោគ

៥-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ការបង្កើត អង្គការបណ្ដាញអន្តរជាតិសម្រាប់ឫស្សី និងផ្ដៅ ។

**៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមិថុនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូច ខាងក្រោម:

**៤.១-មុខងារនីតិកម្ម**

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរ គណៈកម្មការ ព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្ដី ព្រាងច្បាប់ចំនួន០៥ច្បាប់ ។

**៤.២-មុខងារតំណាង**

-បានទទួលពាក្យបណ្ដឹងចំនួន០៣ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន ០២ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០២ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្ដឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន ០១ករណី និងឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០៥ករណី កំពុងពិនិត្យសិក្សាចំនួន០១ករណី ព្រមទាំងទទួលឯកសារពាក្យបណ្ដឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លង ជូនមកគណៈ-កម្មការដើម្បីជូនជ្រាបចំនួន០៥ករណី

-អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តសៀមរាបស្ដីពី ការជំរុញ និង លើកកម្ពស់ការផ្ដល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន និងការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព

-អញ្ជើញចូលរួមសិក្ខាសាលាស្ដីពី ភាពជាអ្នកដឹកនាំក្នុងការត្រួតពិនិត្យការអនុវត្ត ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្ដីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់

-អញ្ជើញចូលរួមសិក្ខាសាលាស្ដីពី ការឈ្វេងយល់អំពីសេចក្ដីព្រាងច្បាប់ស្ដីពី ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត

-អញ្ជើញចូលរួមប្រជុំពិភាក្សាដើម្បីត្រៀមទៅចូលរួមប្រជុំ ASEAN-AIPA

-អញ្ជើញចូលរួមប្រជុំការងារកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ

-អញ្ជើញចូលរួមប្រជុំត្រៀមខ្លឹមសារ និងឯកសារដើម្បីចូលរួមកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំស្ត្រីពិភពលោកឆ្នាំ២០១៩ (W.P.L Summit 2019) នៅប្រទេសជប៉ុន

-អញ្ជើញចូលរួមប្រជុំពិភាក្សាអំពីការកំណត់គម្រោងអាទិភាព សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២ នៅក្រុងព្រះសីហនុ

-អញ្ជើញចូលរួមប្រជុំពិនិត្យ និងពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២០ របស់ព្រឹទ្ធសភា

-អញ្ជើញចុះសួរសុខទុក្ខជនរងគ្រោះក្នុងឧបទ្ទវហេតុរលំអគារកម្ពស់៧ជាន់ នៅខេត្តព្រះសីហនុ

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១០១លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១១៤លើក ។

**៥- កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាទៅបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់ពីវិស័យកសិកម្ម កសិឧស្សាហកម្ម និងវិស័យវិនិយោគអចលនទ្រព្យតាមបែបទំនើប និងពង្រឹងទំនាក់ទំនងសហប្រតិបត្តិការ ដើម្បីនាំមកនូវផលប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំងពីរ នៅសាធារណរដ្ឋប្រជាមានិតចិន

-ឯកឧត្តម **ឆាយ វណ្ណា** អញ្ជើញចូលរួមសន្និសីទមូស្លីមអន្តរជាតិស្តីពី ការចូលរួមសាមគ្គី "The Values of Centrism and Moderation in the Quran and Sunnah" នៅទីក្រុងMakkah ប្រទេសអារ៉ាប់ប៊ីសេអូឌីត

-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី១០របស់ក្រុមអ្នកនយោបាយអាយប៉ា (10-AIPA Caucus) នៅទីក្រុងកូឡាឡាំពួរ នៃប្រទេសម៉ាឡេស៊ី និងចូលរួមកិច្ចពិភាក្សាទល់មុខគ្នារវាងអន្តរសភាអាស៊ាន(អាយប៉ា) និងអាស៊ាន(ASEAN-AIPA Interface Meeting) នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍

-ឯកឧត្តម **ម៉ែន ស៊ីផាន់** អញ្ជើញចូលរួមសិក្ខាសាលាតំបន់សម្រាប់សមាជិកសភាឆ្នាំ២០១៩ ស្តីពី ពាណិជ្ជកម្មអន្តរជាតិ នៅប្រទេសសិង្ហបុរី

-ឯកឧត្តម **អាយ ខន** និងឯកឧត្តម **ខៀវ មុត** អញ្ជើញចូលរួមសិក្ខាសាលាអន្តរក្រសួងឆ្នាំ២០១៩ សម្រាប់សមាជិកសភាមកពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញទទួលឯកឧត្តម JOSE DE VENECIA, JR អតីតប្រធានរដ្ឋសភាហ្វីលីពីនប្រាំអាណត្តិ និងជាប្រធាន ICAPP និងលោក Le Minh Dien ទីប្រឹក្សាស្ថានទូតវៀតណាម ចូលជួបពិភាក្សាការងារ ដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម។/.

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ